ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០២០-សណ.១៧អអក

ភ្នំពេញ, ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ លោក ឃុន ចាន់ធារិទ្ធិ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងផ្នែកខ្លះនៃឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យលោក ឃុន ចាន់ធារិទ្ធិ ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងផ្នែកខ្លះនៃឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យលោក ឃុន ចាន់ធារិទ្ធិ ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់លោក ឃុន ចាន់ធារិទ្ធិ លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោក ឃុន ចាន់ធារិទ្ធិ ដោយប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួមមកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ.................................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក ឃុន ចាន់ធារិទ្ធិ អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលច្បាស់លាស់ប៉ុណ្ណោះ** " ។៚

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៥
## លើឯកសារអាជ្ញាបណ្ណលេខ ២៧៩ ឯអ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ សម្រាប់លោក ឃុន ចាន់ធារិទ្ធិ ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងផ្នែកខ្លះនៃឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

**DECISION ON THE FIFTH REVISION**

TO THE LICENSE DOCUMENT No.279 LD DATED MAY 18, 2010 OF MR. KHUN CHANTHARITH FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF KAMPONG SELA DISTRICT, PREAH SIHANOUK PROVINCE AND KHUM BOEUNG PHREAV, SRE AMBIL DISTRICT, KOH KONG PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី ខែ ឆ្នាំ២០១៧

.. .., 2017